**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៩០ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់សហគមន៍ នៃតំបន់ឧទ្យានជាតិព្រះសីហនុ "រាម" ស្ថិតក្នុងភូមិសាស្ត្រឃុំ រាម ស្រុក ព្រៃនប់ ខេត្ត ព្រះសីហនុ

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**ស ម្រេ ច**

មាត្រា១:

ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ឧទ្យានជាតិព្រះសីហនុ "រាម" លើផ្ទៃដីទំហំ ១៩៣,៦០៤ ហិកតា (មួយរយកៅសិបបីហិកតា និងប្រាំមួយរយបួនអា) ទៅជាតំបន់សហគមន៍ ស្ថិតនៅក្នុងឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។

មាត្រា២:

តំបន់សហគមន៍ក្នុងតំបន់ឧទ្យានជាតិព្រះសីហនុ "រាម" ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធកំណត់ដោយបណ្តាចំណុចគោល ដែលមាននិយាមកាដូចខាងក្រោម:

| Id | N | X | Y | Id | N | X | Y |
|---|---|---|---|---|---|---|---|
| 1 | A | 351858 | 1169567 | 13 | M | 354687 | 1169628 |
| 2 | B | 352079 | 1169408 | 14 | N | 355168 | 1169572 |
| 3 | C | 352138 | 1169553 | 15 | O | 355199 | 1169788 |
| 4 | D | 352256 | 1169888 | 16 | P | 355256 | 1170218 |
| 5 | E | 352368 | 1169878 | 17 | Q | 354579 | 1170332 |
| 6 | F | 352581 | 1169912 | 18 | R | 353798 | 1170461 |
| 7 | G | 352656 | 1169786 | 19 | S | 352961 | 1170289 |
| 8 | H | 352819 | 1169738 | 20 | T | 352268 | 1170146 |
| 9 | I | 352893 | 1169721 | 21 | U | 353380 | 1169592 |
| 10 | J | 352895 | 1169797 | 22 | V | 353378 | 1169412 |
| 11 | K | 353217 | 1169796 | 23 | W | 353732 | 1169433 |
| 12 | L | 354263 | 1169683 | 24 | X | 353569 | 1169602 |

**មាត្រា៣:**

ការកំណត់តំបន់សហគមន៍ស្ថិតក្នុងភូមិសាស្ត្រឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ជាតំបន់គ្រប់គ្រងបម្រើឲ្យការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់សហគមន៍មូលដ្ឋានដែលកំពុងមានសកម្មភាពស្រាប់ រួមមានៈ លំនៅឋាន ស្រែចម្ការ។ រាល់ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឲ្យប្រើប្រាស់ដីធ្លី នៅក្នុងតំបន់សហគមន៍នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន ដោយអនុលោមតាមច្បាប់ភូមិបាល ។

**មាត្រា៤:**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៥:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី .០៧. ខែ .សីហា.. ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ